# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

-------

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងពាណិជ្ជកម្ម

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងសុខាភិបាល

ក្រសួងទេសចរណ៍

លេខ ៖ ៨៦៨ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពីការអនុវត្តន៍ និងការរៀបចំសម្របសម្រួលស្ថាប័នកិច្ច
# នៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ
# ចាប់ពីកសិដ្ឋានផលិត ដល់តុបរិភោគ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងវិស័យទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និង សេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឲ្យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើត នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទ ផលផលិតផលជលផល ដែលកំពុងរងគ្រោះថ្នាក់

- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វសាច់ និងផលិតផលសាច់
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិ លើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសម្រាប់មនុស្ស
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាម អនាម័យ
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

## ផ្នែកទី ១

## គោលបំណង វិសាលភាព និងនិយមន័យ

**ប្រការ ១** :

ប្រកាសនេះ មានគោលបំណង:

- ជំរុញការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រង់សុវត្ថិភាពម្ហូបអាហារ ដើម្បីការពារសុខភាពរបស់អ្នកប្រើប្រាស់ និងលើកកំពស់ភាពប្រកួតប្រជែងក្នុងការនាំចេញផលិតផលម្ហូបអាហារ របស់កម្ពុជា ។
- កំណត់នូវយន្តការស្ថាប័នកិច្ចច្បាស់លាស់មួយ ដើម្បីសម្របសម្រួលការងារ និងកិច្ចសហប្រតិបត្តិការ រវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ ។

ប្រកាសនេះកំណត់គោលការណ៍សំខាន់ៗ ការសម្របសម្រួលស្ថាប័នកិច្ច និងការអនុវត្តន៍របស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារផ្អែកលើមូលដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រច្បាស់លាស់ ប្រសិទ្ធភាពសេដ្ឋកិច្ច និងប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម ។

**ប្រការ ២** :

បទបញ្ញត្តិចែងក្នុងប្រកាសនេះគ្របដណ្តប់តែលើ ម្ហូបអាហារក្នុងគោលបំណងពាណិជ្ជកម្ម និងសកម្មភាពពាក់ព័ន្ធនានា នៅគ្រប់ដំណាក់កាលនៃខ្សែសង្វាក់ផលិតកម្មម្ហូបអាហារ ចាប់តាំងពីសកម្មភាពផលិតកម្មដំបូងនៅកសិដ្ឋាន រហូតដល់ការប្រើប្រាស់ចុងក្រោយរបស់អ្នកប្រើប្រាស់។ ម្ហូបអាហារដែលផលិតក្នុងគោលបំណងប្រើប្រាស់ក្នុងគ្រួសារផ្ទាល់ខ្លួន ឬ ក្នុងគោលបំណងកំសាន្ត ចំណីសត្វ និងសារពាង្គកាយកែច្នៃរស់ (LMOs) មិនត្រូវបានគិតបញ្ចូលក្នុងប្រកាសនេះទេ ។

ក្នុងគោលបំណងពង្រឹងការអនុវត្តន៍ជាជំហានៗ ឆ្ពោះទៅការអនុវត្តន៍សមាហរណកម្មគោលនយោបាយជាតិមួយស្តីពីសុវត្ថិភាពម្ហូបអាហារ ការសម្របសម្រួលស្ថាប័នកិច្ចកំណត់ក្នុងប្រកាសនេះ សំដៅបញ្ជាក់ឲ្យបានច្បាស់លាស់នូវការទទួលខុសត្រូវ និងប្រសិទ្ធភាពនៃការអនុវត្តន៍តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច លើទិដ្ឋភាពខាងក្រោម ៖

- ការរៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ស្តង់ដារ និងបទបញ្ញត្តិបច្ចេកទេសផ្សេងៗ
- ការពង្រឹងការអនុវត្តន៍បញ្ញត្តិកម្មស្តីពីសុវត្ថិភាពម្ហូបអាហារ រួមមានការចុះបញ្ជី ការចេញច្បាប់អនុញ្ញាតឲ្យបង្កើត និងដំណើរការសកម្មភាពធុរកិច្ចម្ហូបអាហារ ការត្រួតពិនិត្យ អធិការកិច្ច និងការអនុវត្តន៍វិធានការណ៍ច្បាប់ផ្សេងៗ
- ការធ្វើការបញ្ជាក់ផ្លូវការ និងការចេញវិញ្ញាបនបត្រ័ដោយសមត្ថកិច្ចឯកទេសផ្សេងៗ
- ការរៀបចំ និងអនុវត្តប្រព័ន្ធវិភាគ និងគ្រប់គ្រងហានិភ័យ និង
- ការប្រមូលព័ត៌មានស្ថិតិសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេសក្នុងគោលបំណងត្រួតពិនិត្យហានិភ័យ។

**ប្រការ ៣** :

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេស និងវាក្យសព្ទសំខាន់ៗ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម ៖

- ម្ហូបអាហារ មានន័យថាសារធាតុ ឬ ផលិតផលទាំងឡាយណា ដែលបានកែច្នៃចទាំងស្រុង ឬ កែច្នៃបឋម ឬ មិនទាន់បានកែច្នៃ ក្នុងគោលបំណងបរិភោគដោយមនុស្ស រាប់ទាំងភេសជ្ជៈ ស្ករកៅស៊ូសម្រាប់ទំពារ ឬសារធាតុផ្សេងៗទៀត ដែលត្រូវប្រើប្រាស់ ក្នុងការផលិត រៀបចំ ឬ ប្រព្រឹត្តិកម្មម្ហូបអាហារ មិនត្រូវរាប់បញ្ចូល ចំណីសត្វ សត្វរស់ លើកលែងតែត្រូវបានដាក់លក់លើទីផ្សារសម្រាប់មនុស្សយកទៅបរិភោគ ភោគផលដំណាំរុក្ខជាតិ នៅមុនពេលប្រមូលផល ផលិតផលឱសថ ដូចចែងក្នុងមាត្រា២ និងមាត្រា៣នៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ ថ្នាំជក់ និងផលិតផលថ្នាំជក់ ផលិតផលណាកូទិច ថ្នាំសណ្តំ គ្រឿងញៀន ព្រមទាំងសំណល់ និងសារធាតុពុលផ្សេងៗ។

- <u>ចំណីសត្វ</u> មានន័យថាសារធាតុ ឬ ផលិតផលផ្សេងៗ រួមទាំងសារធាតុផ្សំបន្ថែមផ្សេងៗ ដែលបានកែច្នៃរួចទាំងស្រុង កែច្នៃបឋម ឬ មិនទាន់បានកែច្នៃ ប្រើប្រាស់ក្នុងគោលបំណង ឲ្យសត្វបរិភោគ ។
- <u>ធុរកិច្ចម្ហូបអាហារ</u> មានន័យថា រាល់សកម្មភាពផ្សេងៗ ទោះក្នុងគោលបំណងរកប្រាក់ចំណេញ ឬ មិនរកប្រាក់ចំណេញអនុវត្តដោយរដ្ឋ ឬ ឯកជន ក្នុងគោលបំណងផលិត កែច្នៃ និងបញ្ជូនចែកចាយម្ហូបអាហារ ។
- <u>ប្រតិបត្តិករធុរកិច្ចម្ហូបអាហារ</u> មានន័យថា រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលទទួលខុសត្រូវលើការធានាអនុលោមភាពតាមបទបញ្ញត្តិជាធរមានផ្សេងៗ ដែលពាក់ព័ន្ធនឹងធុរកិច្ចម្ហូបអាហារ នៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។
- <u>សុវត្ថិភាពម្ហូបអាហារ</u> មានន័យថាការអនុវត្តន៍ដំណើរការធានាថា ម្ហូបអាហារមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់នៅពេលដែល ត្រូវបានយកទៅធ្វើការរៀបចំ ឬ បរិភោគ ស្របតាមកម្មវត្ថុប្រើប្រាស់របស់ម្ហូបអាហារនោះ ។
- <u>ការនាំចូលម្ហូបអាហារ</u> មានន័យថាគ្រប់ម្ហូបអាហារផ្សេងៗ ដែលត្រូវបាននាំឆ្លងកាត់ព្រំដែនចូលមកក្នុងប្រទេស ក្នុងគោលបំណងយកទៅបរិភោគ ឬ ប្រើប្រាស់ ឬ ធ្វើធុរកិច្ចនៅក្នុងប្រទេស។ ទំនិញម្ហូបអាហារដឹកជញ្ជូនឆ្លងកាត់ ពុំត្រូវបានរាប់បញ្ចូលជាការនាំចូលម្ហូបអាហារទេ ។
- <u>ការនាំចេញម្ហូបអាហារ</u> មានន័យថាគ្រប់ម្ហូបអាហារផ្សេងៗ ដែលបានឆ្លងកាត់ព្រំដែន ដើម្បីនាំចេញទៅក្រៅប្រទេស។ ទំនិញម្ហូបអាហារដឹកជញ្ជូនឆ្លងកាត់ពុំត្រូវបានរាប់បញ្ចូលជាការនាំចេញម្ហូបអាហារទេ ។
- <u>ផលិតកម្មដំបូង</u> មានន័យថាសកម្មភាពបង្កបង្កើនផល ការដាំដុះ និងការប្រមូលកសិផលផ្សេងៗរួមទាំងការច្រូតកាត់ ការបេះ ការចិញ្ចឹម ការធ្វើវារីវប្បកម្ម ការច្របាច់យកទឹកដោះ ការប្រមាញ់ និងការនេសាទ ។ លទ្ធផលនៃផលិតកម្មដំបូងរួមមាន ផលផលិតផលជលផល ផលិតផលមានដើមកំណើតពីសត្វ និងកសិផលផ្សេងទៀត ។
- <u>ផល ផលិតផលកសិកម្ម</u> មានន័យថាផល និងផលិតផលដែលទទួលបាន និងមានដើមកំណើតពីសត្វ រុក្ខជាតិ និងវារីសត្វ។
- <u>ផលិតផលមានដើមកំណើតពីសត្វ</u> សំដៅដល់:

  ១. សត្វស្លាប់ ឬ សត្វដែលបានសំលាប់ ឬ ផ្នែកណាមួយរបស់សត្វ ដែលមិនទាន់ត្រូវបានយកទៅចម្អិន ឬ សម្រាប់យកទៅធ្វើការកែច្នៃជាផលិតផលផ្សេងៗ។

  ២. ភ្លុក ស្នែង និងរោមដែលបានកាត់ចេញពីសត្វរស់ ឬ សត្វស្លាប់ដែលមិនទាន់យកទៅកែច្នៃ។

៣. សាច់សត្វ ឬ ផលិតផលទាំងឡាយណា ដែលមានដើមកំណើតពីសត្វសម្រាប់ផ្គត់ផ្គង់ម្ហូបអាហារមនុស្ស ចំណីសត្វ និងប្រើប្រាស់ក្នុងផ្នែកសុខាភិបាល ផ្នែកកសិកម្ម ឬផ្នែកឧស្សាហកម្ម។

- ការកែច្នៃបឋម គឺសំដៅដល់ការបំលែងផល ផលិតផលកសិកម្មតាមរយៈដំណើរការនៃការកែច្នៃមានជាអាទិ៍ ការកិន ការសម្អាត ការបកសំបក ការចិតយកសំបកចេញ ការហាន់ ការបោកបែន ការពោយ ការពិឃាតសត្វ ការពន្លាត់ស្បែក ការហាលសម្ងួត ការស្ងោរ ការផ្អាប់ ការឆ្អើរ ការបង្កក ការវេចខ្ចប់ ការរក្សាទុកការចាត់ថ្នាក់ ដឹកជញ្ជូន និងការកែច្នៃបែបបុរាណ ឬ បច្ចេកវិទ្យាផ្សេងៗទៀត ។ ការកែច្នៃទាំងឡាយ ដែលអនុវត្តនៅក្នុងរោងចក្រធុន តូច មធ្យម ធំ និងសិប្បកម្មដូចមានកំណត់ក្នុងមាត្រា ២ និង ៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ពុំត្រូវរាប់បញ្ចូលថា ជាការកែច្នៃបឋមទេ។
- ការកែច្នៃដោយរោងចក្រសិប្បកម្ម មានន័យថាការផលិតម្ហូបអាហារ ឬ ការកែច្នៃដើម្បីផលិតជាម្ហូបអាហារលើសពីកំរិតការកែច្នៃបឋម ដូចជា៖ ការកិន ការបន្សុទ្ធ ការរំងាប់មេរោគ ការរំលាយចូលគ្នា ការរួមផ្សំ និងការចម្អិន ។ល។ ដែលត្រូវបានអនុវត្តនៅក្នុងរោងចក្រនិងសិប្បកម្ម ។
- ការបញ្ជូនចែកចាយម្ហូបអាហារ មានន័យថាការដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀត និង/ឬ ការស្តុកទុក ម្ហូបអាហារតាមមធ្យោបាយសមស្របណាមួយ ។
- ការលក់ដូរ មានន័យថាការស្នើផ្តល់ឲ្យ ការផ្សាយពាណិជ្ជកម្ម ការស្តុកទុក ការតាំងលក់ ការបញ្ជូន ការផ្ញើបញ្ញើ ឬ ការចែកចាយ ក្នុងគោលបំណងលក់ ឬ ដោះដូរទៅឲ្យបុគ្គលណាមួយ ដូចជាការលក់នៅតាមតូប លក់នៅកសិដ្ឋាន លក់នៅក្នុងផ្សារនៅទីក្រុង ឬទីប្រជុំជន លក់នៅផ្សារតាមផ្លូវ និងលក់នៅផ្សារទំនើប ។ល។ ប៉ុន្តែពុំរាប់បញ្ចូលការលក់នៅកន្លែងប្រើប្រាស់ចុងក្រោយ។
- កន្លែងប្រើប្រាស់ចុងក្រោយ មានន័យថាការប្រើប្រាស់ចុងក្រោយរបស់អ្នកប្រើប្រាស់រួមមានស្តង់លក់ម្ហូបអាហារ កង់ទីន ភោជនីយដ្ឋាន ហាងកាហ្វេ អាហារដ្ឋាននៅតាមសាលារៀន មន្ទីរពេទ្យ ស្ថាប័ន និង គ្រឹះស្ថានផ្សេងៗ និងតូបលក់ម្ហូបអាហារនៅតាមផ្លូវ ។
- អាហារដ្ឋាននិងភោជនីយដ្ឋានទេសចរណ៍ សំដៅដល់អគារ ឬ ទីតាំងដែលរៀបចំឡើងដើម្បីបម្រើសេវាកម្មម្ហូបអាហារ និងភេសជ្ជៈសម្រាប់ភ្ញៀវជាចម្បង។
- ម្ហូបអាហារសម្រាប់គោលបំណងកំសាន្ត មានន័យថាម្ហូបអាហារ ដែលត្រូវបានប្រមូលក្នុងឱកាសនៃការធ្វើកីឡា ឬ ដើម្បីលំហែកំសាន្តផ្សេងៗ ដូចជា កីឡាស្ទូចត្រី កីឡាប្រមាញ់។ល។

## ផ្នែកទី ២
## គោលការណ៍មូលដ្ឋាន

**ប្រការ ៤** :

ម្ហូបអាហារត្រូវបានចាត់ទុកថាពុំមានសុវត្ថិភាព ប្រសិនបើត្រូវបានរកឃើញថា ៖ (១)បង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព និង (២)មិនសមស្របសម្រាប់មនុស្សបរិភោគ ។ ក្នុងការកំណត់វាយតម្លៃថាម្ហូបអាហារណាមួយ បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព ការត្រួតពិនិត្យត្រូវគិតគូរលើ៖

(ក)ផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែង លើសុខភាពបណ្តាលមកពីការប្រើប្រាស់ម្ហូបអាហារ ។

(ខ) ផលប៉ះពាល់បង្កឡើងដោយលទ្ធផលនៃការបង្កជាតិពុល ។

(គ) ភាពងាយទទួលរងផលប៉ះពាល់លើសុខភាពរបស់អ្នកប្រើប្រាស់។

ក្នុងការកំណត់វាយតម្លៃថា ម្ហូបអាហារណាមួយមិនសមស្របសំរាប់មនុស្សបរិភោគ ការត្រួតពិនិត្យ ត្រូវគិតគូរលើ៖

(ក) ភាពអាច ឬ មិនអាចបរិភោគបានដោយមនុស្ស ដោយមូលហេតុមានការបំពុលផ្សេងៗ ឬ មានភាពស្អុយរលួយ ឬ ការខូចគុណភាព។

(ខ) ក្នុងករណីម្ហូបអាហារគ្មានសុវត្ថិភាពត្រូវបានរកឃើញ ក្នុងចំណែកណាមួយនៃឡូ ឬ កញ្ចប់ម្ហូបអាហារ គ្រប់ម្ហូបអាហារនៅក្នុងឡូ ឬ កញ្ចប់នោះ ត្រូវចាត់ទុកថាគ្មានសុវត្ថិភាពដែរ លើកលែងតែ ក្រោយការត្រួតពិនិត្យវាយតម្លៃលម្អិត ពុំមានរកឃើញភស្តុតាងណាមួយបញ្ជាក់ថាផលិតផលទាំងនោះពុំមានសុវត្ថិភាព។

**ប្រការ ៥** :

ក្នុងគោលបំណងជំរុញសុវត្ថិភាពម្ហូបអាហារ ការគ្រប់គ្រង និងត្រួតពិនិត្យម្ហូបអាហារត្រូវអនុវត្តជាចាំបាច់លើរាល់ទិដ្ឋភាពនៅគ្រប់ដំណាក់កាលផលិតកម្មម្ហូបអាហារ ចាប់ផ្តើមពីផលិតកម្មដំបូង រហូតដល់ការប្រើប្រាស់ចុងក្រោយ។ ដើម្បីសំរេចគោលបំណងនេះ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ពាក់ពន្ធ័នឹងការការពារសុវត្ថិភាពម្ហូបអាហារ ត្រូវជំរុញការរៀបចំបណ្តាញស្ថាប័នកិច្ចនិងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ តាមរយៈការសម្របសម្រួលការអនុវត្តន៍ការងារ ការបង្កើតក្របខណ្ឌសហប្រតិបត្តិការវិទ្យាសាស្ត្របច្ចេកទេស ការផ្លាស់ប្តូរព័ត៌មាន ការបង្កើត និងអនុវត្តគម្រោងរួមគ្នា ការផ្លាស់ប្តូរជំនាញឯកទេស និងទម្លាប់អនុវត្តល្អផ្សេងៗ ។

**ប្រការ ៦** :

ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃប្រពន្ធ័គ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ រាល់ការចាត់វិធានការច្បាប់ ការអនុវត្តន៍បញ្ញត្តិកម្មលើម្ហូបអាហារ និងធុរកិច្ចពាក់ព័ន្ធ ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្អែកលើវិធាននៃការវិភាគហានិភ័យ លើកលែងតែក្នុងករណីណាមួយ ដែលវិធាននេះពុំអាចអនុវត្តទៅបាន ។ ការពិនិត្យវាយតម្លៃហានិភ័យ ត្រូវផ្អែកលើភស្តុតាង ឬ ព័ត៌មានវិទ្យាសាស្ត្រ ដែលអាចរកបាននាពេលបច្ចុប្បន្ន និងត្រូវបានអនុវត្តដោយឯករាជ្យ និងមាន តម្លាភាព ។ ការអនុវត្តន៍នេះ ត្រូវធ្វើរួមគ្នាជាមួយនឹងប្រព័ន្ធអនុលោមភាពតាមស្តង់ដារម្ហូបអាហារ ដើម្បីធានាថា រាល់ការអនុវត្តន៍បញ្ញត្តិកម្ម ត្រូវបានសង្កត់ធ្ងន់លើបទបញ្ញត្តិស្តីពីសុវត្ថិភាព ម្ហូបអាហារ។ ការកំណត់បទបញ្ញត្តិស្តីពីសុវត្ថិភាពម្ហូបអាហារ និងស្តង់ដារផ្សេងៗ ដែលតម្រូវឱ្យមាន អនុលោមភាព ត្រូវមានភាពច្បាស់លាស់ ដើម្បីធានាឲ្យការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច មាន ប្រសិទ្ធភាព មានកម្មវត្ថុច្បាស់លាស់ និងផ្តល់អត្ថប្រយោជន៍ដល់ធុរកិច្ចម្ហូបអាហារ ដែលត្រូវបាន ធ្វើការត្រួតពិនិត្យ ។

ក្នុងករណីដែលមានភាពមិនច្បាស់លាស់ខាងវិទ្យាសាស្ត្រ ក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចចាត់វិធានការសមស្របជាបណ្តោះអាសន្ន និងមានតម្លាភាព ដែលមិនបង្កនូវបន្ទុក ឬ របាំង មិនចាំបាច់បន្ថែមដល់ការធ្វើពាណិជ្ជកម្ម ក្រៅពីគោលបំណងធានាសុវត្ថិភាពម្ហូបអាហារ។

**ប្រការ ៧** :

ការធានាសុវត្ថិភាពម្ហូបអាហារ តម្រូវចាំបាច់នូវការចូលរួមទទួលខុសត្រូវពីគ្រប់ភាគីពាក់ព័ន្ធ ចាប់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ផ្នែកឯកជន និងអ្នកប្រើប្រាស់ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចមានតួនាទី:

១-ធ្វើការអប់រំ និងណែនាំដល់អ្នកប្រើប្រាស់ និងប្រតិបត្តិករធុរកិច្ចម្ហូបអាហារអំពីសុវត្ថិភាព ម្ហូបអាហារ។

២-ធ្វើការត្រួតពិនិត្យ អធិការកិច្ច ស្រាវជ្រាវ និងចាត់វិធានការកែលម្អចាំបាច់នានា តម្រូវឲ្យមានការប្រមូលទំនិញចេញពីទីផ្សារ ព្រមទាំងបង្កើតនូវប្រព័ន្ធគ្រប់គ្រងផ្សេងៗ ដើម្បីពង្រឹង សុវត្ថិភាពម្ហូបអាហារ ។

៣-ចាត់វិធានការច្បាប់ផ្សេងៗ រួមទាំងវិធានការរដ្ឋបាល និងការពិន័យតាមច្បាប់ ក្នុងករណី ចាំបាច់ ដែលមិនអាចជៀសវាងបាន ។

ប្រតិបត្តិករធុរកិច្ចម្ហូបអាហារមានតួនាទី:

១-ផលិត និង ចែកចាយម្ហូបអាហារដែលមានសុវត្ថិភាព និងចាត់វិធានការដោះស្រាយ រាល់បញ្ហាពាក់ពន្ធ័សុវត្ថិភាពម្ហូបអាហារ ដែលកើតមានឡើង ។

២-អនុវត្តប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ។

៣-ធានាអនុលោមភាពតាមបទបញ្ញត្តិ និងស្តង់ដារម្ហូបអាហារ

៤-ជូនដំណឹងដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច អំពីបញ្ហាសុវត្ថិភាពម្ហូបអាហារ និងសហការអនុវត្តន៍វិធានការផ្សេងៗ ដើម្បីទប់ស្កាត់ ឬ កាត់បន្ថយហានិភ័យនានា ដែលបង្កឡើងដោយម្ហូបអាហារដែលខ្លួនផលិត។

៥-ធ្វើការឆ្លើយតបភ្លាមៗចំពោះបញ្ហាសុវត្ថិភាពម្ហូបអាហារដែលកើតឡើង។

៦-យកចេញពីទីផ្សារនូវម្ហូបអាហារដែលពុំមានសុវត្ថិភាព ។

អ្នកប្រើប្រាស់អាចចូលរួមក្នុងការពង្រឹងសុវត្ថិភាពម្ហូបអាហារដោយៈ

១-សិក្សាស្វែងយល់អំពីបញ្ហាសុវត្ថិភាពម្ហូបអាហារ និងប្រើប្រាស់តែម្ហូបអាហារណាដែលមានអនុលោមភាពតាមបទបញ្ញត្តិ និងស្តង់ដារម្ហូបអាហារ។

២-ផ្តល់ដំណឹងដល់ប្រតិបត្តិករធុរកិច្ចម្ហូបអាហារ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច អំពីបញ្ហាសុវត្ថិភាពម្ហូបអាហារផ្សេងៗ ។

**ប្រការ ៨**:

ប្រតិបត្តិករធុរកិច្ចម្ហូបអាហារត្រូវកត់ត្រារាល់ព័ត៌មានអំពីអ្នកផ្គត់ផ្គង់ផ្សេងៗរបស់ខ្លួន និងត្រូវផ្តល់ព័ត៌មានទាំងនេះដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ចតាមការតម្រូវ ។ ប្រតិបត្តិករធុរកិច្ចម្ហូបអាហារ ត្រូវធានាថាម្ហូបអាហារមានស្លាកសញ្ញាគ្រប់គ្រាន់ និងត្រឹមត្រូវ ។

**ប្រការ ៩** :

ផ្អែកតាមច្បាប់និងបទបញ្ញត្តិជាធរមាន ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវៈ

១-ចូលរួមក្នុងការបង្កើតគោលនយោបាយ ច្បាប់ បទបញ្ញត្តិ និងស្តង់ដារផ្សេងៗពាក់ព័ន្ធសុវត្ថិភាពម្ហូបអាហារ តាមរយៈការផ្តល់នូវមតិយោបល់វិទ្យាសាស្ត្របច្ចេកទេស លើទិដ្ឋភាពផ្សេងៗ ដែលអាចមានផលប៉ះពាល់ដោយផ្ទាល់ ឬ ប្រយោល លើសុវត្ថិភាពម្ហូបអាហារនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន ។

២-នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវប្រមូលទិន្នន័យ ធ្វើការសិក្សាស្រាវជ្រាវ និងផ្លាស់ប្តូរព័ត៌មានជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងគោលបំណងអនុវត្តប្រព័ន្ធវាយតម្លៃ និងគ្រប់គ្រងហានិភ័យ ។

៣-ជំរុញការបង្កើត និង អនុវត្តវិធីសាស្ត្ររួម ក្នុងការវាយតម្លៃហានិភ័យ ។

៤-ជំរុញការបង្កើត និងអនុវត្តយន្តការទំនាក់ទំនងព័ត៌មាន ប្រកបដោយប្រសិទ្ធភាព អំពីសុវត្ថិភាពម្ហូបអាហារ ។

៥-ជំរុញសង្គតភាព និងសុខដុមនីយភាព នៃបទបញ្ញត្តិបច្ចេកទេសផ្សេងៗ ដែលកំណត់អនុម័តឲ្យប្រើប្រាស់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងៗ ពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ ។

**ប្រការ ១០** :

ការអនុវត្តន៍ប្រព័ន្ធសុវត្ថិភាពម្ហូបអាហារ ត្រូវធានាអនុលោមភាពជាមួយនិងកាតព្វកិច្ចរបស់កម្ពុជា ដែលចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានា ជាពិសេសនៅក្នុងកិច្ចព្រមព្រៀង ជាមួយអង្គការពាណិជ្ជកម្មពិភពលោកអំពីវិធានអនាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងត្រូវធានាសុខដុមនីយភាពជាមួយការអនុវត្តន៍ជាអន្តរជាតិ និងថ្នាក់តំបន់ផ្សេងៗ ដូចជាក្នុងក្របខ័ណ្ឌអាស៊ានជាដើម ។

## ផ្នែកទី ៣
## ការសម្របសម្រួលស្ថាប័នកិច្ចគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ នៅផលិតកម្មដំបូង និង ការកែច្នៃបឋម

**ប្រការ ១១**:

ស្របតាមបទបញ្ញត្តិ និងច្បាប់ជាធរមាន រាល់ការចុះបញ្ជី និង/ឬ ការផ្តល់ច្បាប់អនុញ្ញាតឲ្យបង្កើត និងដំណើរការធុរកិច្ចម្ហូបអាហារ ចាប់ពីផលិតកម្មដំបូង រហូតដល់ការកែច្នៃបឋម ត្រូវអនុវត្តដោយស្ថាប័នមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្នុងការអនុវត្តន៍ការងារនេះ ស្ថាប័នមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធានាផ្តល់ព័ត៌មាន អំពីការចុះបញ្ជី និងការផ្តល់ច្បាប់អនុញ្ញាតធុរកិច្ចម្ហូបអាហារ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៅពេលមានការស្នើសុំ។

**ប្រការ ១២** :

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបំពេញតួនាទីជាស្ថាប័នទទួលខុសត្រូវនាំមុខតែមួយគត់ ក្នុងការដឹកនាំសម្របសម្រួលជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាព នូវបណ្តាតួនាទី និងភារកិច្ច ពាក់ព័ន្ធនឹងម្ហូបអាហារ និងធុរកិច្ចម្ហូបអាហារ ចាប់ពីផលិតកម្មដំបូង រហូតដល់ការកែច្នៃបឋម ដូចខាងក្រោម:

- ការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌបញ្ញត្តិកម្ម ស្តីពីសុវត្ថិភាពម្ហូបអាហារនៅផលិតកម្មដំបូង និងការកែច្នៃបឋម ។
- ការត្រួតពិនិត្យអធិការកិច្ចម្ហូបអាហារ និងធុរកិច្ចម្ហូបអាហារ នៅទីតាំងផលិតកម្មដំបូង និងកែច្នៃបឋម ។

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រង និងអភិវឌ្ឍការជំរុញអនុលោមភាពតាមការតម្រូវនៃបទបញ្ញត្តិស្តីពីសុវត្ថិភាពម្ហូបអាហារ ។
- អនុវត្តកម្មវិធីផ្តល់ការបញ្ជាក់ផ្លូវការ និងផ្តល់វិញ្ញាបនប័ត្រសុខភាព គុណភាព សម្រាប់ការនាំចេញ ម្ហូបអាហារដែលជាផលផលិតផលកសិកម្ម។
- រៀបចំ និងអនុវត្តវិធានការឆ្លើយតបបន្ទាន់ (General Plan for Crisis management) ដើម្បីដោះស្រាយ ការពារទប់ស្កាត់ និងកាត់បន្ថយហានិភ័យដែលកើតមានឡើង ឬ រំពឹងថាអាចនឹងកើតមានឡើង ។

ក្នុងការអនុវត្តន៍តួនាទី និងភារកិច្ចខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវជំរុញឲ្យមានការចូលរួម និងការផ្តល់មតិវិទ្យាសាស្ត្រ (Scientific Opinion) ពីស្ថាប័នឯកទេស និងក្រសួងជំនាញពាក់ព័ន្ធផ្សេងៗតាមការចាំបាច់។ ក្នុងករណីតម្រូវឱ្យមានការចូលរួមត្រួតពិនិត្យ ឬ ធ្វើអធិការកិច្ច ដោយស្ថាប័នឯកទេស ឬ ក្រសួងជំនាញពាក់ព័ន្ធផ្សេងទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្របសម្រួលដល់ការត្រួតពិនិត្យនេះ ឲ្យមានសុខដុមនីយភាព និងមានប្រសិទ្ធភាពស្ថាប័នកិច្ច ។

ក្នុងករណីចាំបាច់ ស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមាន ឬ មានការតម្រូវពីភាគីទីពណាមួយឱ្យមានការផ្តល់ការបញ្ជាក់ ឬ ការចេញវិញ្ញាបនប័ត្រឯកទេសបញ្ជាក់អនុលោមភាពផ្សេងៗ ដែលត្រូវធ្វើដោយស្ថាប័នឯកទេស ឬ ក្រសួងជំនាញពាក់ព័ន្ធផ្សេងទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កលក្ខណៈ និងសម្របសម្រួលជំរុញឲ្យមានការអនុវត្តន៍ទាំងនេះអាចប្រព្រឹត្តទៅបានដោយប្រសិទ្ធភាព ។

**ប្រការ ១៣** :

ក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត មានភារកិច្ចផ្តល់នូវការសហការចូលរួម និងផ្តល់មតិវិទ្យាសាស្ត្រ ឬ ជំនួយបច្ចេកទេសផ្សេងៗពាក់ព័ន្ធនឹងបញ្ហានៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ និងជំនាញឯកទេសរបស់ខ្លួនតាមការស្នើសុំ ដើម្បីធានាថារាល់សេចក្តីសំរេចអំពីវិធានការគ្រប់គ្រងហានិភ័យផ្សេងៗដែលត្រូវអនុម័តឲ្យអនុវត្ត មានប្រសិទ្ធភាព និងត្រូវបានផ្អែកលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់។

ស្របតាមច្បាប់ បទបញ្ញត្តិជាធរមាន និងផ្អែកលើគោលការណ៍ប្រសិទ្ធភាពស្ថាប័នកិច្ច និងកិច្ចសម្រួលពាណិជ្ជកម្ម ក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្សព្វផ្សាយជូនដំណឹងដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវបច្ចុប្បន្នភាព ឬ ការវិវឌ្ឍន៍ផ្សេងៗនៃក្របខ័ណ្ឌបញ្ញត្តិកម្ម ដែលត្រូវអនុវត្តដោយស្ថាប័នរបស់ខ្លួន ពាក់ព័ន្ធនឹងធុរកិច្ចម្ហូបអាហារ នៅផលិតកម្មដំបូង និងការកែច្នៃបឋម ព្រមទាំងបង្កលក្ខណៈដើម្បីជំរុញឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុវត្តនូវមុខងារពង្រឹងអនុលោមភាពតាមក្របខ័ណ្ឌបញ្ញត្តិកម្ម ជំនួសឲ្យស្ថាប័ន ឬ

ក្រសួងទាំងនោះ លើកលែងតែមានការតម្រូវដោយឡែក ឬ មានមូលហេតុសមស្របណាមួយដែលត្រូវអនុវត្តផ្ទុយពីនេះ។

## ផ្នែកទី ៤
## ការសម្របសម្រួលស្ថាប័នកិច្ចគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ នៅដំណាក់កាលកែច្នៃដោយរោងចក្រសិប្បកម្ម

**ប្រការ ១៤**:

ស្របតាមបទបញ្ញត្តិ និង ច្បាប់ជាធរមាន រាល់ការចុះបញ្ជី ឬ ការផ្តល់ច្បាប់អនុញ្ញាតឲ្យបង្កើត និងដំណើរការធុរកិច្ចម្ហូបអាហារ នៅដំណាក់កាលកែច្នៃដោយរោងចក្រសិប្បកម្ម ត្រូវអនុវត្តដោយស្ថាប័នមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ក្នុងការអនុវត្តន៍ការងារនេះ ស្ថាប័នមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធានាផ្តល់ព័ត៌មានអំពីការចុះបញ្ជី និងការផ្តល់ច្បាប់អនុញ្ញាតរោងចក្រ និងសិប្បកម្មម្ហូបអាហារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៅពេលមានការស្នើសុំ។

**ប្រការ ១៥** :

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបំពេញតួនាទីជាស្ថាប័នទទួលខុសត្រូវនាំមុខតែមួយគត់ ក្នុងការដឹកនាំសម្របសម្រួល ជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបណ្តាតួនាទី និងភារកិច្ច ពាក់ព័ន្ធនឹងម្ហូបអាហារ និងធុរកិច្ចម្ហូបអាហារ នៅដំណាក់កាលកែច្នៃដោយរោងចក្រសិប្បកម្មដូចខាងក្រោម៖

- ការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌបញ្ញត្តិកម្មស្តីពីសុវត្ថិភាពម្ហូបអាហារ និងស្តង់ដារម្ហូបអាហារ
- ការត្រួតពិនិត្យ ធ្វើអធិការកិច្ចម្ហូបអាហារ និងធុរកិច្ចម្ហូបអាហារនៅរោងចក្រ និងសិប្បកម្ម
- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍ការជំរុញអនុលោមភាពតាមការតម្រូវនៃបទបញ្ញត្តិស្តីពីសុវត្ថិភាពម្ហូបអាហារ ។
- អនុវត្តកម្មវិធីផ្តល់ការបញ្ជាក់ផ្លូវការ និងផ្តល់វិញ្ញាបនប័ត្រសម្រាប់ការនាំចេញនៃផលិតផលម្ហូបអាហារ ដែលត្រូវបានផលិត ឬ កែច្នៃដោយរោងចក្រសិប្បកម្ម ។
- អនុវត្តកម្មវិធីផ្តល់ការបញ្ជាក់ផ្លូវការ និងផ្តល់វិញ្ញាបនប័ត្រសម្រាប់ការនាំចូលផ្ទាល់ដោយរោងចក្រសិប្បកម្ម ក្នុងគោលបំណងប្រើប្រាស់ក្នុងរោងចក្រ និងសិប្បកម្ម នូវផលិតផលម្ហូបអាហារ ដែលមិនមែនជាផលផលិតផលជលផល ផលិតផលកែច្នៃផលជលផល ផលិផលមានដើមកំណើតពីសត្វ និងកសិផលផ្សេងទៀត ។

- រៀបចំ និងអនុវត្តវិធានការឆ្លើយតបបន្ទាន់ (General Plan for Crisis management) ដើម្បីដោះស្រាយ ការពារទប់ស្កាត់ និងកាត់បន្ថយហានិភ័យដែលកើតមានឡើង ឬ រំពឹងថាអាចនឹងកើតមានឡើង ។

ក្នុងការអនុវត្តន៍តួនាទី និងភារកិច្ចខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវជំរុញឲ្យមានការចូលរួម និងការផ្ដល់មតិវិទ្យាសាស្ត្រ (Scientific Opinion) ពីស្ថាប័នឯកទេស និងក្រសួងជំនាញពាក់ពន្ធ័ផ្សេងៗតាមការចាំបាច់ ។ ក្នុងករណីតម្រូវឲ្យមានការចូលរួមត្រួតពិនិត្យ ឬ ធ្វើអធិការកិច្ចដោយស្ថាប័នឯកទេស ឬ ក្រសួងជំនាញពាក់ព័ន្ធផ្សេងទៀត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវសម្របសម្រួលដល់ការត្រួតពិនិត្យនេះ ឲ្យមានសុខដុមនីយភាព និងមានប្រសិទ្ធភាពស្ថាប័នកិច្ច ។

ក្នុងករណីចាំបាច់ ស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមាន ឬ មានការតម្រូវពីភាគីទីពណាមួយឲ្យមានការផ្ដល់ការបញ្ជាក់ ឬ ការចេញវិញ្ញាបនប័ត្រឯកទេសបញ្ជាក់អនុលោមភាពផ្សេងៗ ដែលត្រូវធ្វើដោយស្ថាប័នឯកទេស ឬ ក្រសួងជំនាញពាក់ព័ន្ធផ្សេងទៀត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបង្កលក្ខណៈ និងសម្របសម្រួលជំរុញឱ្យមានការអនុវត្តន៍ទាំងនេះអាចប្រព្រឹត្តទៅបានដោយប្រសិទ្ធភាព ។

**ប្រការ ១៦** :

ក្រសួងនិងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត មានភារកិច្ចផ្ដល់នូវការសហការចូលរួម និងផ្ដល់មតិវិទ្យាសាស្ត្រ ឬ ជំនួយបច្ចេកទេសផ្សេងៗ ពាក់ព័ន្ធនឹងបញ្ហានៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ និងជំនាញឯកទេសរបស់ខ្លួនតាមការស្នើសុំដើម្បីធានាថា រាល់សេចក្ដីសម្រេចអំពីវិធានការគ្រប់គ្រងហានិភ័យផ្សេងៗ ដែលត្រូវអនុម័តឲ្យអនុវត្តមានប្រសិទ្ធភាព និងត្រូវបានផ្អែកលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់។

ស្របតាមច្បាប់ បទបញ្ញត្តិជាធរមាន និងផ្អែកលើគោលការណ៍ប្រសិទ្ធភាពស្ថាប័នកិច្ច និងកិច្ចសម្រួលពាណិជ្ជកម្ម ក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្សព្វផ្សាយជូនដំណឹងដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នូវបច្ចុប្បន្នភាព ឬ ការវិវឌ្ឍន៍ផ្សេងៗនៃក្របខ័ណ្ឌបញ្ញត្តិកម្ម ដែលត្រូវអនុវត្តដោយស្ថាប័នរបស់ខ្លួន ពាក់ព័ន្ធនឹងធុរកិច្ចម្ហូបអាហារ នៅដំណាក់កាលកែច្នៃដោយរោងចក្រនិងសិប្បកម្ម ព្រមទាំងបង្កលក្ខណៈ ដើម្បីជំរុញឲ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចអនុវត្តនូវមុខងារពង្រឹងអនុលោមភាពតាមក្របខ័ណ្ឌបញ្ញត្តិកម្មជំនួសឲ្យស្ថាប័ន ឬ ក្រសួងទាំងនោះ លើកលែងតែមានការតម្រូវដោយឡែក ឬ មានមូលហេតុសមស្របណាមួយដែលត្រូវអនុវត្តផ្ទុយពីនេះ។

## ផ្នែកទី ៥
## ការសម្របសម្រួលស្ថាប័នកិច្ចគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារនៅលើទីផ្សារ

**ប្រការ ១៧** :

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ័ណ-អាហារ័ណ(កាំកុងត្រូល)នៃក្រសួងពាណិជ្ជកម្ម ត្រូវបំពេញតួនាទីជាស្ថាប័នទទួលខុសត្រូវនាំមុខតែមួយគត់ ក្នុងការដឹកនាំសម្របសម្រួលជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាព នូវកម្មវិធីត្រួតពិនិត្យធុរកិច្ចពាណិជ្ជកម្មលើទីផ្សារ និងបណ្តាភារកិច្ចដូចខាងក្រោម:

- រៀបចំក្របខ័ណ្ឌបទបញ្ញត្តិកម្មពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ និងមូលដ្ឋានគតិយុត្តផ្សេងៗដើម្បីប្រតិបត្តិការរួមគ្នាជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងក្រសួងស្ថាប័នពាក់ព័ន្ធ ។
- ចូលរួមផ្តល់មតិយោបល់ក្នុងការបង្កើតស្តង់ដារផ្សេងៗ ក្នុងគោលបំណងការពារផលប្រយោជន៍អ្នកប្រើប្រាស់ ។
- អនុវត្តវិធានការផ្សេងៗ ចំពោះផលិតផលដែលពុំមានអនុលោមភាពតាមបទបញ្ញត្តិ ស្តីពីសុវត្ថិភាពម្ហូបអាហារ ក្នុងនោះ មានការផ្តល់ព័ត៌មាន និងជំនួយផ្សេងៗ ដើម្បីជំរុញឲ្យមានអនុលោមភាព ការចេញលិខិតព្រមាន និងការពិន័យផ្សេងៗ ការអនុវត្តន៍និតិវិធីច្បាប់ផ្សេងៗ ការបញ្ឈប់លក់ដូរ ការរឹបអូសយកផលិតផល និងការតម្រូវឱ្យប្រមូលផលិតផលចេញពីទីផ្សារ។
- លើកសំណើសុំចាត់វិធានការចាំបាច់ផ្សេងៗ និងតាមដានការអនុវត្តន៍វិធានការទាំងនោះដោយក្រសួងនិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដែលទទួលខុសត្រូវនៅផ្នែកផ្សេងៗនៃខ្សែសង្វាក់ផលិតកម្មម្ហូបអាហារ ។
- ទទួល និង រៀបចំឱ្យមានការឆ្លើយតប ចំពោះបណ្តឹងតវ៉ាផ្សេងៗរបស់អ្នកប្រើប្រាស់ ។
- បង្កើត និង អនុវត្តក្របខ័ណ្ឌការងារសម្រាប់សកម្មភាពត្រួតពិនិត្យលើទីផ្សារឆ្លងដែន ។

ក្នុងការអនុវត្តន៍តួនាទី និងភារកិច្ចខាងលើ អគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម ត្រូវជំរុញឲ្យមានការចូលរួម និងការផ្តល់មតិវិទ្យាសាស្ត្រ (Scientific Opinion) ពីស្ថាប័នឯកទេស និងក្រសួងជំនាញពាក់ព័ន្ធផ្សេងៗតាមការចាំបាច់។ ក្នុងករណីតម្រូវឲ្យមានការចូលរួមត្រួតពិនិត្យ ឬ ធ្វើអធិការកិច្ចដោយស្ថាប័នឯកទេស ឬ ក្រសួងជំនាញពាក់ព័ន្ធផ្សេងទៀត អគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម ត្រូវសម្របសម្រួលដល់ការត្រួតពិនិត្យនេះឲ្យមានសុខដុមនីយភាព និង មានប្រសិទ្ធភាពស្ថាប័នកិច្ច ។

**ប្រការ ១៨**:

ក្រសួង និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត មានភារកិច្ចផ្តល់នូវការសហការចូលរួម និងផ្តល់មតិវិទ្យាសាស្ត្រ ឬ ជំនួយបច្ចេកទេសផ្សេងៗ ពាក់ព័ន្ធនឹងបញ្ហានៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ និងជំនាញឯកទេសរបស់ខ្លួន តាមការស្នើសុំ ដើម្បីធានាថា រាល់សេចក្តីសម្រេចអំពីវិធានការគ្រប់គ្រងហានិភ័យផ្សេងៗ ដែលត្រូវអនុម័តឲ្យអនុវត្តនៅលើទីផ្សារ មានប្រសិទ្ធភាព និងត្រូវបានផ្អែកលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់។

ស្របតាមច្បាប់ និងបទបញ្ញត្តិ និងផ្អែកលើគោលការណ៍ប្រសិទ្ធភាពស្ថាប័នកិច្ច និងកិច្ចសម្រួលពាណិជ្ជកម្ម ក្រសួង និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្សព្វផ្សាយ ជូនដំណឹងដល់អគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្មនូវបច្ចុប្បន្នភាព ឬ ការវិវឌ្ឍន៍ផ្សេងៗ នៃក្របខ័ណ្ឌបញ្ញត្តិកម្ម ដែលត្រូវអនុវត្តដោយស្ថាប័នរបស់ខ្លួនពាក់ព័ន្ធនឹងធុរកិច្ចម្ហូបអាហារនៅលើទីផ្សារព្រមទាំងបង្គុលក្ខណៈផ្សេងៗ ដើម្បីជំរុញឲ្យអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម អាចអនុវត្តមុខងារពង្រឹងអនុលោមភាព តាមក្របខ័ណ្ឌបញ្ញត្តិកម្មជំនួសឲ្យស្ថាប័ន ឬ ក្រសួងទាំងនោះ លើកលែងតែមានការតម្រូវដោយឡែក ឬ មានមូលហេតុសមស្របណាមួយ ដែលត្រូវអនុវត្តផ្ទុយពីនេះ។

## ផ្នែកទី ៦
## ការសម្របសម្រួលស្ថាប័នកិច្ចគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ នៅកន្លែងប្រើប្រាស់ចុងក្រោយ

**ប្រការ ១៩**:

ស្របតាមបទបញ្ញត្តិនិងច្បាប់ជាធរមាន រាល់ការចុះបញ្ជី ឬ ការផ្តល់ច្បាប់អនុញ្ញាតឲ្យបង្កើត និងដំណើរការធុរកិច្ចម្ហូបអាហារ ព្រមទាំងការធ្វើអធិការកិច្ចលើអនុលោមភាពតាមបទដ្ឋានស្តង់ដារទេសចរណ៍ នៅអាហារដ្ឋាននិងភោជនីយដ្ឋានទេសចរណ៍ ត្រូវអនុវត្តដោយស្ថាប័នមានសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍។

ក្នុងការអនុវត្តន៍ការងារនេះស្ថាប័នសមត្ថកិច្ចក្រសួងទេសចរណ៍ត្រូវធានាផ្តល់ព័ត៌មានអំពីការចុះបញ្ជី និងការផ្តល់ច្បាប់អនុញ្ញាតធុរកិច្ចម្ហូបអាហារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូនក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត នៅពេលមានសំណើសុំ។

**ប្រការ ២០** :

ក្រសួងសុខាភិបាល ត្រូវបំពេញតួនាទីជាស្ថាប័នទទួលខុសត្រូវនាំមុខតែមួយគត់ ក្នុងការដឹកនាំសម្របសម្រួលជំរុញអនុវត្តឲ្យមានប្រសិទ្ធភាពនូវភារកិច្ច ពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារនៅកន្លែងប្រើប្រាស់ចុងក្រោយដូចខាងក្រោម៖

- រៀបចំគោលនយោបាយ និងក្របខ័ណ្ឌបញ្ញត្តិកម្មស្តីពីសុខភាព និងស្តង់ដារអនាម័យ
- ចូលរួមផ្តល់មតិក្នុងការបង្កើតស្តង់ដារផ្សេងៗក្នុងគោលដៅការពារនូវសុខភាពរបស់អ្នកប្រើប្រាស់ ។
- រៀបចំ និងអនុវត្តកម្មវិធីជំរុញឲ្យមានអនុលោមភាពតាមបទបញ្ញត្តិស្តីពីអនាម័យ និងការសំអាតសម្លាប់មេរោគ។
- ត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើស្ថានភាព សុខភាព អនាម័យ និងភាពគ្មានចម្លងរោគនៃម្ហូបអាហារ និងធុរកិច្ចម្ហូបអាហារនៅកន្លែងប្រើប្រាស់ចុងក្រោយ។
- អនុវត្តកម្មវិធីផ្តល់ការបញ្ជាក់ផ្លូវការ និងផ្តល់វិញ្ញាបនប័ត្របញ្ជាក់អនុលោមភាពតាមបទបញ្ញត្តិអនាម័យនិងការសម្អាតសម្លាប់មេរោគ សម្រាប់ធុរកិច្ចម្ហូបអាហារនៅកន្លែងប្រើប្រាស់ចុងក្រោយ។
- រៀបចំ និងអនុវត្តវិធានការឆ្លើយតបបន្ទាន់ ដើម្បីដោះស្រាយការពារទប់ស្កាត់ និងកាត់បន្ថយហានិភ័យ ដែលកើតមានឡើងនៅកន្លែងប្រើប្រាស់ចុងក្រោយ។

ក្នុងការអនុវត្តន៍តួនាទី និងភារកិច្ចខាងលើ ក្រសួងសុខាភិបាល ត្រូវជំរុញឲ្យមានការចូលរួម និងការផ្តល់មតិវិទ្យាសាស្ត្រ ពីស្ថាប័នឯកទេស និងក្រសួងជំនាញពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។ ក្នុងករណីតម្រូវឲ្យមានការចូលរួម ត្រួតពិនិត្យ ឬ ធ្វើអធិការកិច្ចដោយក្រសួងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ក្រសួងសុខាភិបាលត្រូវសម្របសម្រួលដល់ការត្រួតពិនិត្យអធិការកិច្ចនេះឲ្យមានសុខដុមនីយភាព និងមានប្រសិទ្ធភាពស្ថាប័នកិច្ច។

ក្នុងករណីចាំបាច់ ស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមាន ឬ មានការតម្រូវពីភាគីទី៣ណាមួយឲ្យមានការផ្តល់ការបញ្ជាក់ ឬ ការចេញវិញ្ញាបនប័ត្រឯកទេសបញ្ជាក់អនុលោមភាពផ្សេងៗ ដែលត្រូវធ្វើដោយស្ថាប័នឯកទេស ឬ ក្រសួងជំនាញពាក់ព័ន្ធផ្សេងទៀត ក្រសួងសុខាភិបាល ត្រូវបង្កលក្ខណៈ និងសម្របសម្រួលជំរុញឲ្យមានការអនុវត្តន៍ទាំងនេះ អាចប្រព្រឹត្តទៅបានដោយប្រសិទ្ធភាព ។

**ប្រការ ២១** :

ក្រសួង និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត មានភារកិច្ចផ្តល់នូវការសហការចូលរួម និងផ្តល់មតិវិទ្យាសាស្ត្រ ឬ ជំនួយបច្ចេកទេសផ្សេងៗ ពាក់ព័ន្ធនឹងបញ្ហានៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ និងជំនាញឯកទេសរបស់ខ្លួន តាមការស្នើសុំ ដើម្បីធានាថា រាល់សេចក្តីសំរេចអំពីវិធានការគ្រប់គ្រងហានិភ័យផ្សេងៗ ដែលត្រូវអនុម័តឲ្យអនុវត្តនៅកន្លែងប្រើប្រាស់ចុងក្រោយមានប្រសិទ្ធភាព និងត្រូវបានផ្អែកលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់។

ស្របតាមច្បាប់ និងបទបញ្ញត្តិ និងផ្អែកលើគោលការណ៍ប្រសិទ្ធភាពស្ថាប័នកិច្ច និងកិច្ចសម្រួលពាណិជ្ជកម្ម ក្រសួង និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្សព្វផ្សាយ ជូនដំណឹងដល់

ក្រសួងសុខាភិបាល នូវបច្ចុប្បន្នភាព ឬ ការវិវឌ្ឍន៍ផ្សេងៗ នៃក្របខ័ណ្ឌបញ្ញត្តិកម្ម ដែលត្រូវអនុវត្តដោយស្ថាប័នរបស់ខ្លួនពាក់ព័ន្ធនឹងធុរកិច្ចម្ហូបអាហារនៅកន្លែងប្រើប្រាស់ចុងក្រោយ ព្រមទាំងបង្កលក្ខណៈផ្សេងៗ ដើម្បីជំរុញឲ្យក្រសួងសុខាភិបាលអាចអនុវត្តមុខងារពង្រឹងអនុលោមភាពតាមក្របខ័ណ្ឌបញ្ញត្តិកម្ម ជំនួសឲ្យស្ថាប័ន ឬ ក្រសួងទាំងនោះ លើកលែងតែមានការតម្រូវដោយឡែក ឬ មានមូលហេតុសមស្របណាមួយ ដែលត្រូវអនុវត្តផ្ទុយពីនេះ។

## ផ្នែកទី ៧
## ការសម្របសម្រួលស្ថាប័នកិច្ចគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ នៅមាត់ច្រកអន្តរជាតិ

**ប្រការ ២២** :

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញតួនាទីជាស្ថាប័នទទួលខុសត្រូវនាំមុខតែមួយគត់ ក្នុងការដឹកនាំសម្របសម្រួលជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការងារត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហារនៅមាត់ច្រកអន្តរជាតិ ។ នៅក្នុងការអនុវត្តន៍តួនាទី និងភារកិច្ចនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវ ៖

- ចាត់វិធានការ និងអនុវត្តន៍តាមបទបញ្ញត្តិ ដែលកំណត់ដោយប្រកាសអន្តរក្រសួង និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗពាក់ព័ន្ធនឹងការនាំចូល និងនាំចេញម្ហូបអាហារ ស្តីពីការអនុវត្តន៍កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ។
- បំពេញតួនាទីជាស្ថាប័ននាំមុខ ក្នុងការធ្វើអធិការកិច្ចត្រួតពិនិត្យបឋមលើម្ហូបអាហារដែលនាំចូលមកក្នុងប្រទេសនៅមាត់ច្រកអន្តរជាតិ ដើម្បីវាយតម្លៃថា តើផលិតផលគួរត្រូវអនុញ្ញាតឲ្យនាំចូល ឬ តម្រូវឲ្យមានការចូលរួមត្រួតពិនិត្យដោយក្រសួងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ផ្អែកលើមូលដ្ឋានលក្ខណៈវិនិច្ឆ័យនៃកម្រិតហានិភ័យ។
- ផ្លាស់ប្តូរព័ត៌មានអំពីអ្នកនាំចូលម្ហូបអាហារជាមួយអគ្គនាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម ក្នុងករណីម្ហូបអាហារត្រូវបាននាំចូលមកលក់ក្នុងទីផ្សារ ឬ ក្រសួងនិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ក្នុងករណីម្ហូបអាហារត្រូវបាននាំចូលក្នុងគោលបំណងផ្សេងក្រៅពីនេះ។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់បង្កើតលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យ (Setting up risk selectivity criteria) ។
- ជូនដំណឹងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អំពីការអនុញ្ញាតឲ្យនាំចូលម្ហូបអាហារផ្សេងៗ ក្នុងករណីពិនិត្យឃើញ ឬ សង្ស័យថាអាចមានហានិភ័យ ។

ក្នុងករណីសង្ស័យថាអាចមានហានិភ័យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវជំរុញឲ្យមានការចូលរួម និងការផ្តល់យោបល់វិទ្យាសាស្ត្របច្ចេកទេសពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

ពាក់ព័ន្ធផ្សេងទៀត។ ក្នុងករណីតម្រូវឲ្យមានការធ្វើអធិការកិច្ច និងត្រួតពិនិត្យដោយក្រសួងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវសម្របសម្រួលដល់ការត្រួតពិនិត្យនេះ ឲ្យធ្វើឡើងរួមគ្នាតែមួយលើកស្របតាមបញ្ញត្តិ មាត្រា៥ ជំពូក២ និងមាត្រា១៤ ជំពូក៣ នៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ។

ក្នុងករណីមានការតម្រូវដោយប្រទេសដែលទទួលការនាំចូល ក្រសួងនិងស្ថាប័នមានសមត្ថកិច្ចផ្សេងៗមានតួនាទី ផ្តល់នូវការបញ្ជាក់ និងចេញវិញ្ញាបនប័ត្រស្តីពីសុវត្ថិភាពម្ហូបអាហារដែលត្រូវនាំចេញស្របតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រសួងពាណិជ្ជកម្មត្រូវទទួលខុសត្រូវក្នុងការសិក្សាស្រាវជ្រាវ ប្រមូលចងក្រងព័ត៌មានពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ និងលក្ខខ័ណ្ឌនាំចូលទីផ្សារ នៅតាមបណ្តាប្រទេសទទួលការនាំចូលនានា។

**ប្រការ ២៣** :

ក្រសួង និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗត្រូវសហការ និងផ្តល់ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានូវព័ត៌មានអំពីម្ហូបអាហារ ឬ មុខសញ្ញាប្រតិបត្តិករធុរកិច្ចម្ហូបអាហារដែលជាប់ហានិភ័យខ្ពស់ ឬ ចូលរួមក្នុងការត្រួតពិនិត្យអធិការកិច្ចលើបញ្ហានានា នៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន ។

ស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមាន និងផ្អែកលើគោលការណ៍ប្រសិទ្ធភាពស្ថាប័នកិច្ច ក្រសួងនិងស្ថាប័នមានសមត្ថកិច្ចនានា ត្រូវផ្សព្វផ្សាយជូនដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានូវបច្ចុប្បន្នភាព ឬ ការវិវឌ្ឍន៍នៃបញ្ជីមុខទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដែលពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ ព្រមទាំងបង្កលក្ខណៈជំរុញឲ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បំពេញបានប្រកបដោយប្រសិទ្ធភាព នូវភារកិច្ចនៃការគ្រប់គ្រងហានិភ័យនៅមាត់ច្រកអន្តរជាតិ។

## ផ្នែកទី ៨
## ការរៀបចំស្ថាប័នកិច្ចសម្រាប់ការអនុវត្តន៍កិច្ចសម្របសម្រួល ក្នុងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ

**ប្រការ ២៤** :

ការសម្របសម្រួលការងារគ្រប់គ្រងសុវត្ថិភាពម្ហូបអាហាររបស់ក្រសួង និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗ និងការពិនិត្យពិភាក្សាលើគ្រប់បញ្ហា និងទិដ្ឋភាពផ្សេងៗនៃសុវត្ថិភាព ម្ហូបអាហារក្នុងក្របខ័ណ្ឌនៃកិច្ចសម្របសម្រួលស្ថាប័នកិច្ចកំណត់ក្នុងប្រកាសនេះ ត្រូវអនុវត្តក្នុងក្របខ័ណ្ឌ នៃ

គណៈកម្មាធិការអន្តរក្រសួងសម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផល និងសេវាកម្ម។

**ប្រការ ២៥ :**

ប្រកាសនេះមានប្រសិទ្ធភាព និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ចម_ប្រសិទ្ធ

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

ស៊ុយ_សែម

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ច័ន្ទ-សារុន

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

ម៉ម_ប៊ុនហេង

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

ថោង_ខុន

**ចម្លងជូន:**
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-រាជធានី

"ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ